# មជ្ឈមណ្ឌលឯកសារកម្ពុជា

BBI0097

## សម្ភាសន៍ជាមួយឈ្មោះ គង់ វឿន ភេទប្រុស អាយុ៥៦ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានអនុសេនាធំកងកាំភ្លើងធំតំបន់២៤
## មុខងារបច្ចុប្បន្នៈ កសិករ
## ស្រុកកំណើតនៅភូមិព្រះស្រែ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង
## សព្វថ្ងៃរស់នៅភូមិសាស្តា ឃុំសាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង
## ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០០:៥៩:២៣
## ២៩ទំព័រ

ដានី ៖ ចឹងពូដឹងប្អូនខ្ញុំចង់ស្គាល់លោកពូ ពូឈ្មោះអីដែរ ពេញ?

វឿន ៖ បាទ! ខ្ញុំឈ្មោះ គង់ វឿន ។

ដានី ៖ គង់ វឿន?

វឿន ៖ បាទ!

ដានី ៖ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

វឿន ៖ អាយុ៥៦ហើយ ។

ដានី ៖ អាយុ៥៦?

វឿន ៖ ៥៦ ។

ដានី ៖ ពូស្រុកកំណើតកើតជានៅជាដែរ?

វឿន ៖ ខ្ញុំនៅភូមិព្រះស្រែ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង ។

ដានី ៖ ភូមិព្រះស្រែ ។ ចឹងសព្វថ្ងៃ ពូរស់នៅក្នុងភូមិឃុំអីដែរ?

វឿន ៖ សព្វថ្ងៃខ្ញុំរស់នៅភូមិសាស្តា ឃុំសាស្តា ស្រុកសំពៅលូន ខេត្តបាតដំបង ។

ដានី ៖ គ្រួសារលោកពូឈ្មោះអីដែរ?

វឿន ៖ ឈ្មោះ រត្ន័ វឿន ។

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

វឿន ៖ អាយុ៥៥ ។

ដានី ៖ គាត់ស្រុកកំណើតអ្នកភូមិនៅណាដែរ?

វឿន ៖ គាត់អ្នកនៅភូមិបឹង មិនដឹងឃុំស្អីទៀត ស្រុកគងពិសី កំពង់ស្ពឺ ។

ដានី ៖ គងពិសី កំពង់ស្ពឺ ។ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

វឿន ៖ ខ្ញុំមានកូន៥ ប្រុស៤ ស្រី១ ។

ដានី ៖ សព្វថ្ងៃនេះ ពូប្រកបមុខរបររកស៊ីធ្វើអីដែរ?

វឿន ៖ ខ្ញុំធ្វើចំការ ។

ដានី ៖ ធ្វើចំការធ្វើអីខ្លះទៅ?

វឿន ៖ អត់ មានដាំដំឡូងឆ្នាំនឹង ។

ដានី ៖ ដាំដំឡូងសុទ្ធ អត់មានដាំអីទៀតទេ?

វឿន ៖ អត់មានដាំអីទៀតទេ ។

ដានី ៖ អត់មានធ្វើស្រូវធ្វើអីទេ?

វឿន ៖ អត់ ។

ដានី ៖ ចុះមានគួនាទីអីផ្សេងទៀតដែរអត់?

វឿន ៖ បាទ! អត់មាន ។

ដានី ៖ ឪពុកម្ដាយពូគាត់នៅដែរ ឬក៏គាត់?

វឿន ៖ គាត់ស្លាប់អស់ហើយ ។

ដានី ៖ គាត់ស្លាប់អស់ហើយ ឪពុកម្ដាយពូ?

វឿន ៖ បាទៗ ។

ដានី ៖ ឪពុកឈ្មោះអីទៅ?

វឿន ៖ ឈ្មោះ ព្រាប គង់ ។

ដានី ៖ ព្រាប គង់?

វឿន ៖ បាទ!

ដានី ៖ គាត់ស្លាប់តាំងពីអង្កាល់?

វឿន ៖ ស្លាប់តាំង១៩៧៩ ។

ដានី ៖ ស្លាប់៧៩?

វឿន ៖ បាទ!

ដានី ៖ ពេលដែលយួនចូលនឹង?

វឿន ៖ បាទ!

ដានី ៖ ម្ដាយ?

វឿន ៖ ម្ដាយ ឆួន នឿន ស្លាប់ហើយ ។

ដានី ៖ គាត់ស្លាប់ពីអង្កាល់ដែរ?

វឿន ៖ ស្លាប់២០០០ប៉ុន្មានទេ ២០០០ ។

ដានី ៖ ២០០០ដាង?

វឿន ៖ បាទ! ២០០០ដាង ២០០៨ ២០០៩ ២០០៨ ។

ដានី ៖ គាត់ស្លាប់ដោយសារជម្ងឺ?

វឿន ៖ ជម្ងឺចាស់ ។

ដានី ៖ ចុះឪពុក ៧៩ គាត់ឈឺដែរ?

វឿន ៖ ឈឺ ចាស់ ។

ដានី ៖ បងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

វឿន ៖ បងប្អូនបង្កើត៣នាក់ ។

ដានី ៖ ៣នាក់?

វឿន ៖ ស្រី១ ប្រុស២ ។

ដានី ៖ ពូកូនទីប៉ុន្មាន?

វឿន ៖ ទី៣ ។

ដានី ៖ កូនពៅគេ?

វឿន ៖ បាទ!

ដានី ៖ កាលពីក្មេងៗលោកពូបានរៀនសូត្រដល់ណាដែរ?

វឿន ៖ កាលឆ្នាំអឺ!៦៦រៀនដល់ឆ្នាំ៦៩ រៀន៣ឆ្នាំ ។

ដានី ៖ រៀនដល់ឆ្នាំ៦៩ រៀននៅសាលាណា?

វឿន ៖ សាលាវត្តព្រះស្រែនឹង ។

ដានី ៖ ពូចេះអាន ចេះសរសេរច្បាស់ដែរ?

វឿន ៖ បាទ! អានបានកើត ។

ដានី ៖ ដល់ពេលឆ្នាំ៦៩ ពេលពូឈប់ទៅ ពូធ្វើអីទៀតទៅ?

វឿន ៖ បាទ! ធ្វើស្រែជាមួយម្ដាយឪពុក ។

ដានី ៖ ពេលធ្វើស្រែជាមួយឪពុកម្ដាយដល់ឆ្នាំណាទៅ?

វឿន :	ខ្ញុំរហូតដល់ឆ្នាំ១៩៧៣ ។

ដានី :	ដល់៧៣ពូធ្វើអីទៀតទៅ?

វឿន :	អឺ! ចូលធ្វើទាហាន ។

ដានី :	ចូលធ្វើទាហានខាងណា?

វឿន :	ខ្មែរក្រហមនឹង ។

ដានី :	កាលនឹងពូចូលយ៉ាងម៉េច យើងស្ម័គ្រចិត្តចូលឬក៏យាងម៉េច?

វឿន :	បាទ! កាលនឹងស្ម័គ្រចិត្ត ។

ដានី :	ម៉េចបានពូស្ម័គ្រចិត្តចូលកងទ័ព?

វឿន :	ចុះបើគេទាំងអស់គេទៅហើយ យើងនៅក៏មិនកើត ។

ដានី :	តាមគេតាមឯង?

វឿន :	តាមឯងទៅ ។

ដានី :	កាលជំនាន់ពូស្ម័គ្រចិត្តចូលគ្នាច្រើន?

វឿន :	ទៅជាមួយខ្ញុំតែ៣នាក់នឹង ក្នុងភូមិ ។

ដានី :	ទៅ៣នាក់កាលនឹង កាលពេលពូចូលឆ្នាំ៧៣ ពូអាយុប៉ុន្មាន?

វឿន :	អាយុ១៧ ។

ដានី :	យើងចូលដំបូងទៅនៅណាទៅ?

វឿន :	ចូលដំបូងទៅហ្វឹកហាត់នៅ ។

ដានី :	នៅណា?

វឿន :	ហ្នឹងនៅទ័ពនៅតំបន់កាលនឹង តំបន់យើងហៅតំបន់២៤ ។ ។

ដានី :	ហាត់នៅតំបន់២៤?

វឿន :	បាទ!

ដានី :	តំបន់២៤នៅណា?

វឿន :	នៅក្នុងខេត្តព្រៃវែង ។

ដានី :	ហ្វឹកហាត់នៅតំបន់២៤រយៈពេលប៉ុន្មានទៅ?

វឿន :	នៅ៣ខែ ។

ដានី :	ហាត់អីខ្លះទៅនៅ?

វឿន :	ហាត់ខាងក្បួនយុត្តិសាស្ត្រ សង្គ្រាម ។

ដានី ៖ ចឹងហាត់ក្បួនយុត្តសាស្ត្រសគ្រាមពាវែខ ហើយយ៉ាងម៉េចទៀតទៅ?

វឿន ៖ បាទ! គេបញ្ជូនទៅអង្គភាពទ័ពថ្មើរជើង ។

ដានី ៖ នៅណា?

វឿន ៖ នៅអឺ! ចង់ភ្លេចដូចជាយូរហើយ នៅក្នុងទ័ពតំបន់ដែរ ប៉ុនគ្រាន់វរៈសេនាតូចវាប៉ុន្មាន ភ្លេចហើយ ។

ដានី ៖ តំបន់២៨?

វឿន ៖ តំបន់២៨ ។

ដានី ៖ នៅហ្នឹងរយៈពេលប៉ុន្មានទៅ?

វឿន ៖ ខ្ញុំអឺ! រហូត១៩៧៧ ។

ដានី ៖ នៅទ័ពតំបន់រហូត?

វឿន ៖ បាទ! និយាយរួមរហូតដល់៧៩តែម្តង ។

ដានី ៖ នៅទ័ពតំបន់រហូត?

វឿន ៖ បាទ!

ដានី ៖ អត់មានទៅភូមិភាគ អត់មានទៅមជ្ឈមអីនឹងគេ?

វឿន ៖ បាទ!

ដានី ៖ ចឹងអឺ! ដូចថាតាំងពីយើងហាត់ហើយ យើងនៅកងទ័ពថ្មើរជើងរបស់តំបន់ កាលនឹងអង្គភាពលោកពូឈរជើងនៅណា?

វឿន ៖ នៅខាងត្បូងអ្នកលឿង ។

ដានី ៖ ម្តុំណា?

វឿន ៖ ម្តុំពាមជរ បាទ!ម៉ាដួរនឹង ។

ដានី ៖ នឹងយើងក្នុងអង្គភាពនឹងជាកងពល ឬអត់ទេ?

វឿន ៖ អឺ! កាលនឹង នៅក្នុងកាំភ្លើងធំ កងវរៈសេនាតូចកាំភ្លើងធំ ។

ដានី ៖ កងវរសេនាតូចកាំភ្លើងធំ?

វឿន ៖ បាទ!

ដានី ៖ ពូប្រធានវរៈសេនាតូចកាំភ្លើងធំដែរ?

វឿន ៖ អឺ!មិនដឹងអីទេ វាភ្លេចអស់ហើយ យូរហើយ មិនសូវបាននឹកនាពីរឿងនឹង ភ្លេចអស់ហើយ ។

ដានី ៖ ចុះកាលនឹងកងពល អត់មានកងពលទេ?

វឿន ៖ កង ដឹងកាលនឹង វាមិនដឹងថារៀបកងពលអីយ៉ាងម៉េចទេកាលនឹង ខ្ញុំដូចជានៅក្នុងវរៈសេនាតូចដំបូង ខ្ញុំនៅវរសេនាតូចលេខ១ ដល់ក្រោយមកបានខ្ញុំទៅវរសេនាតូចលេខ៧វិញ ។

ដានី ៖ ចុះវរសេនាធំនោះពូ?

វឿន ៖ វរសេនាធំខ្ញុំភ្លេចអស់ហើយកាលនឹង មិនដឹងថា ។ កាលនឹងនៅឯករាជ្យទេ របស់តំបន់ទេ ។

ដានី ៖ ពីណាគេគណៈតំបន់?

វឿន ៖ កាលនឹង អឺ!តាឈូក ។ ។

ដានី ៖ ពូស្គាល់គាត់ច្បាស់ដែរ?

វឿន ៖ បាទ!

ដានី ៖ កាលនឹងពូប្រធានវរៈសេនាតូចកាំភ្លើងធំ?

វឿន ៖ ទេ! ខ្ញុំអត់មានកាន់វរៈអីទេ កូនទាហានគេដែរ ។

ដានី ៖ ចុះពូស្គាល់ចាន់ ចក្រីដែរ?

វឿន ៖ ធ្លាប់ស្គាល់ ។

ដានី ៖ ចាន់ ចក្រី គាត់អីខាងអីគេ?

វឿន ៖ អឺ!

ដានី ៖ ពូមិនមែននៅក្នុងកងពលរបស់ចាន់ ចក្រីទេ?

វឿន ៖ អឺ! មិនដឹងថាទៅនៅខាង ប៉ុនដំបូងនឹងចាន់ ចក្រីនឹង ដូចជាកាលនឹងដូចគាត់កាន់ទ័ព ក៏មិនដឹងខ្ញុំភ្លាប់មិនសូវបាន ។

ដានី ៖ បាទ! គាត់កងពល?

វឿន ៖ កងពលណា ។

ដានី ៖ កងពល១០០ប៉ុន្មាន ១៦២?

វឿន ៖ អត់ចាំ ។

ដានី ៖ តែលោកពូនៅក្រោមតំបន់ ចំនុះឲ្យតាឈូក?

វឿន ៖ បាទ!

ដានី ៖ ចឹងកងទ័ពលោកពូនៅខាងត្បូងអ្នកលឿង នៅខាងពាមជរនៅធ្វើអីខ្លះទៅ?

វឿន ៖ បាទ! និយាយចឹងនៅសម័យសង្គ្រាមនៅវ៉ៃខាងនឹង ។

ដានី ៖ វ៉ៃជាមួយខាងណា?

វឿន ៖ ទាហានលន់ នល់ ។

ដានី ៖ លន់ នល់ ពីខាងអ្នកលឿងនឹង ពីខាងណាពីខាងលិចទន្លេ ឬក៏ខាង?

វឿន ៖ ខាងកើតទន្លេៗ នៅតាមនេះ ។

ដានី ៖ ពូវ៉ៃយូរ វ៉ៃដល់ពេលណា?

វឿន ៖ រហូតដលល់ឆ្នាំ៧៥ ។

ដានី ៖ វ៉ៃចូលមកអ្នកលឿងនឹងម៉ង ឬក៏ម៉េច?

វឿន ៖ ចូលអ្នកលឿង ដល់ក្រោយមកយើងវ៉ៃអ្នកលឿងហើយ បានទៅព្រៃវែងទៀត ។

ដានី ៖ បានវ៉ៃចូលព្រៃវែងទៀត?

វឿន ៖ បាទ!

ដានី ៖ ដល់ពេលអ្នកលឿងវ៉ៃបានពេលណា?

វឿន ៖ មិនដឹងថ្ងៃណា ខែណាទេ ។

ដានី ៖ ក្នុងឆ្នាំ៧៥ដែរ ឬក៏វ៉ៃជាច់មុនទៀត?

វឿន ៖ ត្រឹម៧៥នឹង ។

ដានី ៖ ត្រឹម៧៥?

វឿន ៖ ដឹងខែប៉ុន្មានអីប៉ុន្មាន វាយូរហើយ ។

ដានី ៖ ចុះដល់ពេលវ៉ៃបានហើយបានទៅអ្នកព្រៃវែង?

វឿន ៖ បានទៅព្រៃវែង ។

ដានី ៖ វ៉ៃព្រៃវែងបានពីរអន្លាល់ទៀត?

វឿន ៖ ខ្ញុំចាំមិនបានទេ តែមិនទៅរយៈពេលយូរអីប៉ុន្មាន ។

ដានី ៖ ចឹងវ៉ៃព្រៃវែងបានហើយ យើងវ៉ៃចូលភ្នំពេញទៀត ឬក៏អត់ទេ?

វឿន ៖ អត់ទេ ខ្ញុំអត់ទេ នៅតែខាងកើតនឹង ។

ដានី ៖ កាលនឹងពូមានត្រូវរបួសអីដែរអត់ កាលពីវ៉ៃនៅឆ្នាំនោះ?

វឿន ៖ បាទ! អត់ទេ ។

ដានី ៖ អត់មានត្រូវអីទេ?

វឿន ៖ បាទ!

ដានី ៖ វៃរហូតដល់បែកភ្នំពេញឆ្នាំ៧៥ទៅ?

វឿន ៖ បាទ!

ដានី ៖ កាលនឹងពូមានតួនាទីអីហើយ កាលពេលយើងវៃបាន យើងវៃអ្នកលឿងចូលដល់ព្រៃវែង?

វឿន ៖ ខ្ញុំតួនាទីជាអនុសេនាតូចប៉ុននឹង ។

ដានី ៖ អនុសេនាតូច កងហា ។ ដល់ពេលយើងវៃបានព្រៃវែង យើងរំដោះភ្នំពេញឆ្នាំ៧៥ហើយ កាលនឹងអង្គភាពរបស់ពូឈរជើងនៅណា?

វឿន ៖ កាលនោះខ្ញុំ អឺ! ត្រូវគេបញ្ជូនឲ្យទៅរៀនបើកបរនេះ ។

ដានី ៖ រៀនបើកបរយន្តហោះ?

វឿន ៖ ឡាន ។

ដានី ៖ គេបញ្ជូនឲ្យពូទៅរៀនបើកបរឡាននៅណាទៅ?

វឿន ៖ នៅខាងតំបន់២៨នឹងដែរ ។

ដានី ៖ តំបន់២៨នៅណាទៅ?

វឿន ៖ នៅស្រុកព្រះស្តេច ។

ដានី ៖ នៅខាងចក្រីអីនឹង?

វឿន ៖ អត់ទេ នៅតាំងល្ហ រៀននៅនឹង ។

ដានី ៖ តាំងល្ហ ស្រុកព្រះស្តេច?

វឿន ៖ បាទ!

ដានី ៖ ហ្នឹងមន្ទីរ ៗ តំបន់២៨?

វឿន ៖ បាទ! មន្ទីរខាងគេហៅស្ទីគេ ខាងឡាននឹងនៅនឹង ។

ដានី ៖ ពូរៀនបើកបរនៅនឹងយូរទេ?

វឿន ៖ រៀន៦ខែ ។

ដានី ៖ ដល់ពេលពូរៀន៦ខែយ៉ាងម៉េចទៀតទៅ?

វឿន ៖ បាទ! មកអង្គភាពវិញ ។

ដានី ៖ មកអង្គភាពខាងកងទ័ពវិញ?

វឿន ៖ បាទ!

ដានី ៖ មកអង្គភាពកងទ័ពនៅណា?

វឿន ៖ កាលនឹងនៅការកៅភ្លើងធំរបស់តំបន់ ។

ដានី ៖ បាទ! តំបន់២៨?

វឿន ៖ បាទ! តំបន់២៨ ។

ដានី ៖ តែមកនៅណាអង្គភាព កាលនឹងយើងទៅរៀនបើកបរនៅស្រុកព្រះស្ដេច ដល់ពេលយើងចប់ពីស្រុកព្រះស្ដេច?

វឿន ៖ មកអង្គភាពវិញ ។

ដានី ៖ អង្គភាពឈរជើងនៅណា?

វឿន ៖ នៅស្វាយឧត្ដម ក្បែរនឹងឯង ។

ដានី ៖ ក្បែរណា?

វឿន ៖ បាទ! ក្បែរល្វា ។

ដានី ៖ ដល់ពេលនៅអង្គភាព ពូធ្វើអីទៅកាលនឹង?

វឿន ៖ អឺ! សម័យនោះគ្មានស្អីធ្វើស្រែឲ្យអង្គភាពនឹង ។

ដានី ៖ ធ្វើស្រែ ចុះលោកពូរៀនបើកឡាន ម៉េចបានទៅធ្វើស្រែវិញ?

វឿន ៖ អឺ! កាលនឹងមកឧទាហរណ៍ថាទៅរៀន៣នាក់ចឹង ដូច្នេះខ្ញុំមកក៏អត់មានតួនាទីអីខាងបើកឡាននឹងដែរ ។ ហើយនៅនឹងអង្គភាពធម្មតា ២នាក់នោះគេមានតួនាទីនៅបើកឡានរបស់អង្គភាពនឹង ។

ដានី ៖ បើកឲ្យអ្នកណា?

វឿន ៖ អង្គភាពដដែលនឹង ។

ដានី ៖ បើកឡានឲ្យអង្គភាព?

វឿន ៖ បាទ! នៅអង្គភាពដដែល អង្គភាពកងកាំភ្លើងធំ ។

ដានី ៖ បើកឡានធំ ឡានតូច?

វឿន ៖ ឡានដឹកកាំភ្លើងធំ ។

ដានី ៖ តែពូអត់បើកទេ?

វឿន ៖ បាទ!

ដានី ៖ ចឹងមកអង្គភាពវិញ ធ្វើស្រែរហូតដល់ពេលណាទៅ?

វឿន ៖ ដល់ឆ្នាំ១៩៧៧មិនដឹង បានគេបញ្ជូនខ្ញុំទៅវៃព្រំដែនយួននឹង៧៧មិន ៧០ប៉ុន្មានមិនដឹងខ្ទង់៧៧ ៧៨មិនដឹងទេ ។

ដានី ៖ បញ្ជូនទៅវៃនៅព្រំដែន?

វឿន ៖ បាទ!

ដានី ៖ បញ្ជូនទៅវៃនៅព្រំដែនម្តុំណា?

វឿន ៖ មុនដំបូងនៅ ព្រំប្រទល់ស្វាយរៀង នៅស្វាយរនោង ។

ដានី ៖ បាទ!នៅណា?

វឿន ៖ ស្វាយរនោង ។

ដានី ៖ កាលនឹងអគ្គិភាពយ៉ាងម៉េច ដល់ពេលយើងបញ្ជូនទៅវៃ?

វឿន ៖ កាលនឹងមកដក ពួកខ្ញុំទៅថ្នល់ថ្មើរជើងវិញ ។

ដានី ៖ ទៅថ្មើរជើង ប៉ុន្តែយើងនៅក្នុងកងតំបន់ដដែល ឬក៏យើងផ្លាស់ប្តូរអគ្គិភាពហើយ?

វឿន ៖ ខាងនឹងមិនថាយ៉ាងម៉េច វាភ្លេច ។

ដានី ៖ បានន័យថាពូនៅអគ្គិភាពរបស់តំបន់២៨ដដែល ឬក៏យើងលែង ដល់ពេលវៃយួនយើងផ្លាស់ប្តូរ?

វឿន ៖ នៅៗអគ្គិភាពនៅដដែលទេ បាទ!មិនទាន់មានផ្លាស់ប្តូរអីទេ ។

ដានី ៖ មេអីនៅដដែលទេ?

វឿន ៖ បាទ!

ដានី ៖ កាលនឹងយើងឡើងតាមកងពល ឬយ៉ាងម៉េច?

វឿន ៖ តាមមើលភ្លេចហើយខ្ញុំមិនចាំ មិនដឹងវរៈសេនាធំ ឬក៏កងពលទេ យូរពេកទៅ ។

ដានី ៖ ដល់ពេលឆ្នាំ៧៣ទៅវៃនៅខាងទល់ដែន នៅខាងស្វាយរៀង ខាងស្វាយរនោងអីនឹង ពូនៅកន្លែងនឹងយូរទេ?

វឿន ៖ មិនជាយូរប៉ុន្មាន តាមមើលមិនដល់ម៉ាឆ្នាំ ។

ដានី ៖ មិនដល់ម៉ាឆ្នាំ?

វឿន ៖ បាទ! យួនបុកចូលមកនឹង ។

ដានី ៖ យួនចូលមក?

វឿន ៖ បាទ!

ដានី ៖ កាលនឹងពូ ពេលទៅវៃអីនឹងអត់មានត្រូវរបួសអីទេ?

វឿន ៖ នៅៗមិនទាន់ ។

ដានី ៖ ចុះពូកាលនឹងយើងមានព្រឹត្តិការណ៍គេខាងបូព៌ាត្រូវបានគេចោទថាក្បត់ ហើយកម្មាភិបាលធំៗ កងទ័ពម៉ាចំនួនធំត្រូវបានគេចាប់?

វឿន ៖ បាទ!

ដានី ៖ គេសម្លាប់ កាលនឹងពូព្រឹត្តិការណ៍នឹងពូបានដឹងដែរ?

វឿន ៖ បាទ! ដឹង ប៉ុន្តែអត្តភាពខ្ញុំដូចជាមិនមានអីទេ ។

ដានី ៖ អត់មានអីទេ?

វឿន ៖ បាទៗ ។

ដានី ៖ កាលនឹងដូចកម្មាភិបាលអីកងទ័ពអីត្រូវបានគេចាប់ ដូចជាពិសេស តាឈូក, ចាន់ ចក្រីអី, គេចាប់មុនគេ?

វឿន ៖ បាទ!

ដានី ៖ កាលនឹងពូដូចថាយើងធ្វើការពាក់ព័ន្ធជាមួយគាត់ដែរ ចឹងកាលនឹងយ៉ាងម៉េចដែរ យើងរួចខ្លួន ហើយក៏គេយ៉ាងម៉េច?

វឿន ៖ ទេ! កាលនឹងរួចខ្លួនមិន អត់នេះ ។

ដានី ៖ ចុះពូដឹងថាគេចាប់មូលហេតុអីៗដែរ?

វឿន ៖ អឺ! អត់ដឹងដែរ អត់ដឹងរឿងខាងលើៗខ្ញុំអត់ដឹង មិនដឹងមូលហេតុអី ។

ដានី ៖ តែកងទ័ពភាគច្រើនគេចាប់ដែរ?

វឿន ៖ បាទ! គេចាប់ បើខ្ញុំអត់អី ។

ដានី ៖ ពូដឹងថាមូលហេតុអីបានយើងរួចខ្លួនអត់អី?

វឿន ៖ មិនដឹងថាមូលហេតុអីដែរ ។

ដានី ៖ អត់ដឹង?

វឿន ៖ បាទ!

ដានី ៖ ពីព្រោះបន្ទាប់ពីគេចាប់តានៅ, តាអឺ!តាឈូក ហើយនឹងចាន់ ចក្រីអីហើយ ក្រោយមកទៀតបានគេចាប់ខាងភូមិភាគដូចជា សោ ភឹម ដូចជាកងពល កងទ័ពអីភាគច្រើនទៀតគេចាប់ទៀត ។ ភាគច្រើនខាងបូព៌ាគេចាប់ភាគច្រើនចង់ទាំងអស់ ។

វឿន ៖ បាទ!

ដានី ៖ ចុះដូចថាពូរួចនឹង ពូអត់ដឹងមូលហេតុអីបានយើងអត់សូវ?

វឿន ៖ បាទ! អត់ដឹង ព្រោះអគ្គភាពកាលនឹងគ្នាមិនដល់១០០នាក់ទេ គ្នា៣០នាក់ជាងកាំភ្លើងធំ ហើយគ្នាអត់មានអីផង ។

ដានី ៖ អត់មានអីទាំងអស់?

វឿន ៖ បាទ!

ដានី ៖ ដូចពូមានតួនាទីដែរ យើងមានកាលនឹងពេលដែលយើងវ៉ៃ៧៥ហើយ ពូមានតួនាទីអនុសេនាតូច?

វឿន ៖ បាទ!

ដានី ៖ ដល់ពេលវ៉ៃព្រំដែន ពូមានតួនាទីអីគេ ឡើងតួនាទីទៀត?

វឿន ៖ នឹងមកដល់ព្រំដែននេះ ហើយក៏ ។

ដានី ៖ អត់ទេ កាលវ៉ៃនៅ?

វឿន ៖ ឯវ៉ៃនោះ ។

ដានី ៖ វ៉ៃព្រំដែនយួន?

វឿន ៖ នៅអនុសេនាតូចដដែល ។

ដានី ៖ អត់មានឡើងអនុសេនាធំអីទេ?

វឿន ៖ បាទ! អត់មានទេ បានត្រឹមនឹង ។

ដានី ៖ វ៉ៃនៅនឹង ជិតម៉ាឆ្នាំ បានយួនបុកចូលមក?

វឿន ៖ បាទ!

ដានី ៖ ដល់ពេលយួនបុកចូលមក យ៉ាងម៉េចទៅ?

វឿន ៖ នឹងខ្ញុំនៅអគ្គភាពត្រូវចល័តមកលិចរហូត ។

ដានី ៖ ចល័តមកខាងណា?

វឿន ៖ មកឆ្លងទន្លេមេគង្គមក ឡើងមកអី!ខាងទន្លេមកកាត់ទន្លេបាសាក់ ឡើងមកដល់កំពង់ស្ពឺនេះ ។

ដានី ៖ ឡើងមកកំពង់ស្ពឺទៀត?

វឿន ៖ បាទ!

ដានី ៖ កាលនឹងពូមានប្រពន្ធនៅ?

វឿន ៖ នៅទេ ។

ដានី ៖ អត់ទាន់មានទេ?

វឿន : បាទ!

ដានី : កាលនឹងធ្វើកងទ័ពកងអី យើងខស្សាហ៍ទៅលេងស្រុកភូមិ ទៅលេងផ្ទះឪពុកម្ដាយអត់?

វឿន : ពីមុនបានទៅម្ដងម្កាល់អត់ ២-៣ដងដែរ តាំងពីចូលមក ។

ដានី : បាទ! កាលពូនៅធ្វើកងទ័ពនៅខាងកើតទន្លេមេគង្គអីនឹង ខស្សាហ៍ទៅដែរ?

វឿន : បាទ!

ដានី : ទៅ២-៣ដងដែរ ។ ចឹងដល់ពេលយួនចូលមកដល់ឆ្នាំ៧៩ ពេលយើងកងទ័ពចេះដកមក ខាងលិច មកដល់កំពង់ស្ពឺហើយយ៉ាងម៉េចទៀតទៅ?

វឿន : កាលនឹងមកវៃនៅកំពង់ស្ពឺ ខ្ញុំត្រូវរបួស ។

ដានី : វៃនៅកំពង់ស្ពឺ?

វឿន : បាទ!

ដានី : ពូត្រូវរបួសនៅកន្លែងណា?

វឿន : បាទ! ត្រូវដៃ ។

ដានី : ត្រូវដៃកន្លែងណា?

វឿន : បាក់ដៃ ។

ដានី : បាទ! ត្រូវគ្រាប់អីអានឹង?

វឿន : កាំភ្លើងដៃ អាការ ។

ដានី : ឆ្នាំណានឹង?

វឿន : អឺ!ក្នុងឆ្នាំដដែល ឆ្នាំ៧៩នឹង ។

ដានី : ដល់ពេលពូត្រូវរបួសដៃ យើងទៅដេកពេទ្យ ទៅព្យាបាលនៅណាទៅ ព្រោះកាលនឹងយើង ច្របូកច្របល់ហើយ យួនចូលមក ។ យើងទៅព្យាបាលណាទៅ?

វឿន : ខ្ញុំមក ទៅដេកពេទ្យនៅមកដល់អមលាំងនេះ ។

ដានី : ដេកពេទ្យនៅអមលាំង?

វឿន : បាទ! នៅអមលាំង ។

ដានី : ដេកពេទ្យនៅនឹងរយៈពេលប៉ុន្មានទៅ?

វឿន : ឆាប់ដែរទេ ប្រហែលជាម៉ាអាទិត្យអីនឹង ហើយខ្ញុំរត់មកទៀតមក ។

ដានី : រត់មកទៀត កាលនឹងមិនទាន់ជាស្រួលបួល?

វឿន : បាទ! នៅទេ មិនទាន់ជាទេ ។

ដានី ៖ យើងរត់យ៉ាងម៉េច ត្រូវដើរចេះ យើងដើរបាន?

វឿន ៖ ដើរបាន ។

ដានី ៖ រត់មកណាទៀតទៅ?

វឿន ៖ ខ្ញុំឡើងមកដល់ថៃ ដល់អីនែក! ហៅអីទេ ជិតកោះកុងនោះ ។

ដានី ៖ ដល់ពេលរត់មកនឹង អន្តរភាពពូនៅដដែល ឬក៏វា?

វឿន ៖ អត់ទេ បែកគ្នាអស់ហើយ ។

ដានី ៖ បែកបាក់អស់?

វឿន ៖ បាទ!

ដានី ៖ ពូចូលទៅក្នុងអីវិញ?

វឿន ៖ អានឹងខ្ញុំមកដេកពេទ្យ រត់តាមពេទ្យនឹង ។

ដានី ៖ រត់តាមពេទ្យមក?

វឿន ៖ បាទ!

ដានី ៖ ចូលដីថៃ នៅកន្លែងកោះកុង?

វឿន ៖ បាទ!

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅ?

វឿន ៖ ក្រោយមកបាននៅនឹងប្រហែលម៉ាខែដឹង នៅដីថៃកោះកុងនឹង បានខ្ញុំមកវិញ ឡើងមកវិញមកនៅដីយើងវិញ មកនៅនេះ ។

ដានី ៖ យើងណា?

វឿន ៖ នៅយី ។ !កាលនឹងអូរអន្ទក់ ។ ឯត្បូងនេះ ។

ដានី ៖ នៅកាប៊ីន?

វឿន ៖ កាប៊ីន មិនដឹងគេហៅស្អីទៀត ឥឡូវ ។

ដានី ៖ ខាងត្បូងនឹង?

វឿន ៖ បាទ!

ដានី ៖ មកចូលនឹង ហើយយើងធ្វើអីទៀតទៅ?

វឿន ៖ កាលនឹងខ្ញុំនៅអន្តរភាពពិការ ។

ដានី ៖ អន្តរភាពពិការ?

វឿន ៖ បាទ!

ដានី :	កាលនឹងពូនៅតែដៃទេ?

វឿន :	បាទ!

ដានី :	អន្តភាពពិការជាមួយពីណា?

វឿន :	ជាមួយតាគាំៗ មេខ្ញុំ ។

ដានី :	តាគាំ គាត់ពិការដែរ?

វឿន :	បាទ!

ដានី :	គាត់មេ គ្នាច្រើនទេពិការ?

វឿន :	ច្រើន ម៉ាវវះគេរៀបហើយ វរសេនាតូចពិការនឹង ។

ដានី :	តាគាំគាត់នៅណាឥឡូវ?

វឿន :	គាត់នៅៗយើងនេះ គាត់ខាងអធិការស្រុក គាត់ខាងសមាជិកស្អីមិនដឹង ។

ដានី :	គាត់ពិការនៅណាដែរ តាគាំ?

វឿន :	បាទ?

ដានី :	គាត់ពិការអីដែរ?

វឿន :	ហ៉ើ! ត្រង់នឹងមិនដឹងគាត់ត្រូវត្រង់ណាទេ ប្រហែលជាឆ្អឹងជំនីរតាមមើល បើវាបាក់ឆ្អឹងជំនីរ ។

ដានី :	ចឹងពូមកនៅជាមួយគាត់នៅក្នុងពិការ?

វឿន :	បាទ! នៅបានរយៈពេលខ្លីទេ ។

ដានី :	ហើយម៉េចទៀតទៅ?

វឿន :	កាលនឹងក្រោយមក បានខ្ញុំទៅនៅដំរំស្រះកែវវិញ ។

ដានី :	យ៉ាងម៉េចទៀតទៅ?

វឿន :	ក្រោយមកទៀតបានខ្ញុំត្រឡប់ឡើងពីស្រះកែវមកនៅយើងនេះ ។

ដានី :	នៅណា?

វឿន :	នៅភូមិចំការល្ហុងនេះ ដំបូងបន្ទាប់ពីឡើងពីនោះមកនៅចំការល្ហុង ។

ដានី :	ឆ្នាំណាមកឡើងចំការល្ហុង?

វឿន :	ទេ! ក្នុង៧៩ដែរ ចុង មិនដឹងខែប៉ុន្មាន ប៉ុនចុងជិតដាច់ ។

ដានី :	នៅចំការល្ហុងវិញ?

វឿន :	បាទ!

ដានី ៖ នៅចំការល្ហុងធ្វើអីទៀតទៅ?

រឿន ៖ ទេ! កាលនោះខ្ញុំ អឺ!កាលនឹងមកនៅឃាមអឺ!ចូលមកដែលអន្តភាព ការពារអ្នកទោសនៅនឹងគេហៅមន្ទីរសន្តិសុខទៅចុះ ។

ដានី ៖ អូ! មកនៅការពារអ្នកទោស នៅមន្ទីរសន្តិសុខ នៅជាមួយតាចាន់?

រឿន ៖ បាទ!

ដានី ៖ ឥឡូវគេហៅអីគេ ហៅចំការល្ហុងនឹង?

រឿន ៖ បាទ!

ដានី ៖ ចឹងតាំងពី៧៩មក ពូមកនៅជាមួយតាចាន់រហូត?

រឿន ៖ បាទ!

ដានី ៖ ចឹងនៅអឺ!កន្លែងនឹងអ្នកទោសច្រើន នៅកន្លែងចំការ?

រឿន ៖ មានច្រើន ។

ដានី ៖ អ្នកទោសមកពីណាមក?

រឿន ៖ ជួនកាលមានទាហានខ្មែរ មានអ្នកនៅនេះចាស់ក៏មាន ។

ដានី ៖ អ្នកចាស់ៗនឹងគេចាប់ដែរ?

រឿន ៖ មានការខុសឆ្គងខ្លះគេចាប់ ។

ដានី ៖ ខុសឆ្គងអីគេ?

រឿន ៖ ជួនកាលគ្នា ទេ!មិនដឹងថាជារឿងអីខ្លះទេ មិនដឹងជាក្តាប់អារឿងនឹងវាមិនបាន ព្រោះខ្ញុំជាអ្នកដឹងបញ្ហានឹងគ្រាន់មានភារកិច្ចការពារតែប៉ុននឹង ។

ដានី ៖ អឺ! ពូអ្នកការពារអ្នកទោស?

រឿន ៖ អត់ ។

ដានី ៖ ពូពីមុនមកពូស្គាល់តាចាន់ដែរ?

រឿន ៖ អត់ស្គាល់ទេ ។

ដានី ៖ តាចាន់ គាត់អ្នកស្រុកកំណើតនៅស្វាយរៀង?

រឿន ៖ បាទ!

ដានី ៖ កាលនឹង ពីមុនមកកាលពូនៅស្វាយរៀន នៅព្រៃវែងអី មានស្គាល់គាត់ទេ?

រឿន ៖ អត់ទេ អត់ ។

ដានី ៖ ចុះម៉េចបានយើងមក ដូចថាពូមកដល់នឹងបានធ្វើការជាមួយគាត់?

វឿន ៖ កាលនឹង ខ្ញុំចេញពីស្រះកែវមក អឺ! គាត់ដឹងថាមានកម្លាំងចេញពីស្រះកែវមក គាត់ឲ្យកូនចៅគាត់ទៅចាំទទួល អ្នកណាស្ម័គ្រចិត្តមកនៅជាមួយគាត់ក៏មកនៅនឹងទៅ ។ ហើយកាល នោះគោលដៅរបស់ខ្ញុំមកទៅកន្លែងអគ្គភាពពិការវិញដដែល ។ ហើយទទួលអ្នកស្គាល់គ្នា ហៅមកក៏មកនៅជាមួយគេទៅ ។

ដានី ៖ បាទ! ពីណាគេ?

វឿន ៖ កាលនឹងដូចធឿន សំ ធឿន ។

ដានី ៖ សំ ធឿន?

វឿន ៖ បាទ!

ដានី ៖ គាត់ហៅមកនៅជាមួយ?

វឿន ៖ បាទ!

ដានី ៖ ធឿន គាត់ធ្វើអីមកនៅ?

វឿន ៖ កាលនឹងគាត់គ្មានស្អីទេ គាត់នៅ គាត់មកមុនខ្ញុំ គាត់នៅស្រះកែវដែរកាលនឹង ប៉ុនគាត់មកមុនខ្ញុំ ។ ខ្ញុំចេញមកក្រោយចឹង គាត់នៅសួរខ្ញុំមក ។

ដានី ៖ គាត់មានតួនាទីអីជាមួយតាចាន់ដែរ?

វឿន ៖ អត់ទេ ។

ដានី ៖ កាលនៅមន្ទីរសន្តិសុខនឹង គេហៅមន្ទីរសន្តិសុខអីគេ ចំការល្ហុង ឬក៏ឈ្មោះអីផ្សេង?

វឿន ៖ ហ៎! កាលនឹងគេហៅមន្ទីរ២៣ ។

ដានី ៖ មន្ទីរ២៣សម្រាប់អឺ! និយាយទៅមន្ទីរ២៣នឹងរបស់ពីណាគេដូចថា?

វឿន ៖ របស់តាកន ។

ដានី ៖ តាកន គាត់អ្នកបង្កើតមន្ទីរនឹង?

វឿន ៖ បាទ!

ដានី ៖ សុន សេន គាត់នៅនឹងដែរ តាសុន សេន?

វឿន ៖ ពីមុនគាត់អត់នៅនឹង ក្រោយមកម៉េចទេ ។

ដានី ៖ មិនមែនតាសុន សេន អ្នកបង្កើតទេ តាកនអ្នកបង្កើត?

វឿន ៖ អឺ! បង្កើតនឹង តាកនគាត់នៅនឹង គាត់ទទួលខាងនឹង នៅលើគាត់ ។

ដានី ៖ ប៉ុន្តែមន្ទីរនឹង តាចាន់ គាត់អ្នកធ្វើប្រធាន?

វឿន ៖ បាទ!

ដានី ៖ មន្ទីរនឹងកើតតាំងពីអង្កាល់មក?

វឿន ៖ អឺ! តាំងពី មិនដឹងប៉ុន្មានទេ បើខ្ញុំមកពីស្រះកែវវិញ ឃើញមាននៅនឹងហើយ ។

ដានី ៖ បាទ! ៧៩នឹងឃើញមាននៅនឹងហើយ?

វឿន ៖ បាទ!

ដានី ៖ មានអ្នកទោសច្រើនទេ កាលនឹង?

វឿន ៖ កាលនឹងវាមិនច្រើនទេ ។

ដានី ៖ ប្រហែលប៉ុន្មានទៅ?

វឿន ៖ ជួនកាល៨-១០នាក់ ជួនកាលក៏ចេញទៅអស់ទៅ ។

ដានី ៖ ភាគច្រើនទាហានពីនៅខាងក្នុង ទាហានមកពីខាងក្នុងយើងចាប់បានយកមកដាក់នឹងដែរ?

វឿន ៖ បាទ!

ដានី ៖ ប្រជាជនអី?

វឿន ៖ ទេ! ប្រជាជនមិន ច្រើនទាហាន ដែលប្រជាជនយើងនៅនេះមានការខុសឆ្គងអីក៏មានចាប់ យកមកក្រោយឲ្យត្រឡប់ទៅផ្ទះវិញទៅ ។

ដានី ៖ ចុះកងទ័ពយើង កងទ័ពខាងយើងខ្មែរក្រហមនៅនឹងចាប់ដែរ?

វឿន ៖ មានចាប់ ឲ្យតែខុស ។

ដានី ៖ ឲ្យតែខុសចាប់ដែរ?

វឿន ៖ បាទ!

ដានី ៖ ខាងទាហានខាងក្នុងក៏ចាប់?

វឿន ៖ បាទ!

ដានី ៖ ប្រជាជនក៏ចាប់?

វឿន ៖ បាទ!

ដានី ៖ ដល់ពេលទោសធ្ងន់ធ្ងរគេសម្លាប់ដែរ?

វឿន ៖ ទេ! មិនបានដឹងដែរ ប៉ុនភាគច្រើនដឹងថា នេះទៅដោះលែងទៅវិញ ។ សូម្បីទាហានខ្មែរក៏ ទៅដោះលែងចេញក្រៅ ។ ខ្លះធ្វើទាហានរដ្ឋឥឡូវក៏មាន ។

ដានី ៖ ធ្វើទាហានដល់ពេលចេញពីទាហានខ្មែរ ចូលធ្វើទាហានខ្មែរក្រហមម្តង?

វឿន ៖ បាទ!

ដានី ៖ ហើយកាលនឹងអ្នកដែលនៅធ្វើការនៅមន្ទីរ២៣នឹង តាចាន់ គ្នាប៉ុន្មាននាក់ទៅ គ្នាច្រើនទេ?

វឿន ៖ ជាដំបូងគ្នាមិនច្រើនប៉ុន្មានទេ ។

ដានី ៖ ប្រហែលប៉ុន្មាននាក់?

វឿន ៖ កាលនឹងចែកជា២ក្រុម ម៉ាក្រុមមិនដល់១០នាក់ផង ។

ដានី ៖ ចែកជា២ក្រុមៗម៉េចគេ?

វឿន ៖ ២ក្រុមៗសម្រាប់យាមនឹង ។

ដានី ៖ សម្រាប់យាម តាចាន់ គាត់អត់យាមទេ?

វឿន ៖ បាទ! គាត់យាមអី ។

ដានី ៖ គាត់ធ្វើអី គាត់អ្នកសួរចម្លើយអ្នកទោស?

វឿន ៖ បាទ!

ដានី ៖ តាចាន់ គាត់អ្នកសួរផ្ទាល់ខ្លួនគាត់ម៉ង?

វឿន ៖ បាទ! សួរផ្ទាល់ខ្លួនគាត់ ។

ដានី ៖ ចុះតាកន គាត់ដែលទៅមើល?

វឿន ៖ អត់ មិនដែល ។

ដានី ៖ សុន សេន?

វឿន ៖ អត់ ។

ដានី ៖ ចុះពូនៅធ្វើនឹងរហូតដល់ពេលណា?

វឿន ៖ ខ្ញុំនិយាយរួមរហូតដល់សមាហរណកម្មនឹង ។

ដានី ៖ នៅកន្លែងគុកគេនៅកន្លែងណាទៅ?

វឿន ៖ នៅ ។

ដានី ៖ កន្លែងណា?

វឿន ៖ ទៅពីនេះ អាផ្លូវកែងមកនឹង ។

ដានី ៖ ឥឡូវនៅក្នុងភូមិចំការល្ហុង?

វឿន ៖ បាទ! នៅភូមិចំការល្ហុង ។

ដានី ៖ ជិតផ្ទះតាចាន់ដែរ?

វឿន ៖ មកកើត ។

ដានី ៖ កើតផ្ទះចាន់?

វឿន ៖ បាទ!

ដានី ៖ តាចាន់ ផ្ទះគាត់នៅភូមិចំការល្ហុងនឹង?

វឿន ៖ បាទ!

ដានី ៖ ចឹងកន្លែងគុកនឹងមានរហូតដល់ពេលសមាហរណកម្ម?

វឿន ៖ បាទ!

ដានី ៖ អ្នកទោសនៅតែមានច្រើន នៅចាប់ហូរហែលចឹង?

វឿន ៖ បាទ!

ដានី ៖ តែពូអត់ដឹងថា គេមានទោសខ្លះគេសម្លាប់អីទេ?

វឿន ៖ បាទ!

ដានី ៖ ចុះពូយាមនៅនឹងម៉េចអត់ដឹង ព្រោះយើងអ្នកយាមនៅនឹង យើងអ្នកស្គាល់ច្បាស់ដឹងរឿង?

វឿន ៖ ព្រោះដល់កំណត់យើងឃើញថាគាត់ដោះលែងឲ្យទៅអន្តភាពវិញ ឬក៏ទៅនេះវិញទៅ ដឹងតែប៉ុននឹង ។

ដានី ៖ ចុះពូយាមនៅនឹង មានតួនាទីអីដែរ បើយើងធ្វើតាំងពី៧៩មក?

វឿន ៖ អានឹងបើយើងនិយាយទៅក្រោយមក បានខ្ញុំត្រូវរបួសទៀត ៧៩នឹង ។ ខ្ញុំត្រូវរបួសភ្នែកនេះ ។

ដានី ៖ អូ! ឆ្នាំ៧៩នឹង?

វឿន ៖ បាទ!

ដានី ៖ ត្រូវរបួសនៅណា?

វឿន ៖ នៅនឹងឯង ជាន់មីននៅចំការល្ហុង ។

ដានី ៖ ពេលពូធ្វើការ ធ្វើនៅយាមអ្នកទោសហើយនឹង?

វឿន ៖ បាទ!

ដានី ៖ យាមហើយពូទៅជាន់មីនរបស់ខាងណា?

វឿន ៖ មីន គ្នាឯងដាក់ៗតាមផ្លូវ ។

ដានី ៖ ដាក់តាមផ្លូវ ទៅជាន់មីនយើងនេះម៉េចបានមកត្រូវដល់ភ្នែកវិញ?

វឿន ៖ ខ្ញុំនៅក្រោយគេ ។

ដានី ៖ ខ្ទាត់អំបែងមកត្រូវ?

វឿន ៖ ខ្ទាត់អំបែងត្រូវ ។

ដានី ៖ ចុះអ្នកជាន់?

វឿន ៖ អ្នកជាន់ស្លាប់ ។

ដានី ៖ ពូមិនមែនអ្នកជាន់ទេ?

វឿន ៖ បាទ!

ដានី ៖ ស្លាប់ប៉ុន្មាននាក់ទៅ?

វឿន ៖ ស្លាប់មួយ ។

ដានី ៖ ពូអំបែងត្រូវតែភ្នែក អត់មានត្រូវណាទៀតទេ?

វឿន ៖ ត្រូវច្រើនដែរ ម៉ាខាងនេះប៉ុននេះ តែចូលភ្នែកចូលទាំងពីរ ។

ដានី ៖ តែពូភ្នែកម្ខាងខាងនេះមើលឃើញដែរ មើលឃើញច្បាស់ដែរ?

វឿន ៖ មើលឃើញ ទេ! បានជិតៗ ដោយសារទៅវះភ្នែកនៅបាត់ដំបងសោះបានមើលឃើញ វាស្មើរតែទាំងអស់ហើយភ្នែក ។

ដានី ៖ ដល់ពេលពូត្រូវភ្នែក ពូទៅដេកពេទ្យនៅណា?

វឿន ៖ យី កាលនឹងដេកនៅ ដំបូងដេកនៅបឹងបេង ។

ដានី ៖ បឹងបេងខាងម៉ាឡៃ?

វឿន ៖ បាទ!

ដានី ៖ និយាយរួមកាលនឹងពូចូលធ្វើខាងអ្នកយាមអ្នកទោសនឹង បានរយៈពេលប៉ុន្មាន បានត្រូវជាន់មីន ត្រូវរបួសត្រូវអី?

វឿន ៖ បានប្រហែលជាជិតម៉ាឆ្នាំដែរនឹង ។

ដានី ៖ ជិតម៉ាឆ្នាំដល់ឆ្នាំប៉ុន្មាន?

វឿន ៖ ឆ្នាំ៨០ បានខ្ញុំត្រូវរបួស ចូលមកពីស្រះកែវមក ៧៩ទេ ។

ដានី ៖ ដល់ពេលត្រូវរបួស ពូព្យាបាលប៉ុន្មានបានមកវិញ រយៈពេលប៉ុន្មានទៅព្យាបាលនៅបឹងបេង?

វឿន ៖ ប្រហែលជា២-៣ខែ ភ្នែកនឹងមើលមិនឃើញទេ ឃើញតិចៗ ។

ដានី ៖ តិចៗ ប៉ុន្តែពូមកធ្វើការវិញ មកយាមអ្នកទោសវិញ?

វឿន ៖ អត់ទេ ឈប់ហើយ ។

ដានី ៖ ដល់ពេលពូមកព្យាបាលវិញ មកធ្វើអី?

វឿន ៖ គ្រាន់រស់នៅអន្តភាពនឹងដែរ ដដែល ។

ដានី ៖ អន្តភាពកន្លែងឃាមអ្នកទោស ដដែល?

វឿន ៖ បាទៗ ។

ដានី ៖ កាលនឹងតាចាន់ គាត់ធ្វើប្រធាន ពីណាគេអនុប្រធានគាត់ តាចាន់?

វឿន ៖ នៅអី ពូមុល ឥឡូវគាត់នៅអូរអន្លក់ ។

ដានី ៖ ខាងណាអូរអន្លក់ ខាង?

វឿន ៖ កាប៊ីន ។

ដានី ៖ ឈ្មោះមុល?

វឿន ៖ បាទ!

ដានី ៖ ចុះពូមកនៅអន្តភាពនេះធ្វើអីទៅ បន្ទាប់ពីពិការ?

វឿន ៖ ខ្ញុំបន្ទាប់ពីពិការទៅ គេឲ្យទទួលខាងមីនៗ ។

ដានី ៖ មីនៗម៉េច?

វឿន ៖ ទទួលដឹកនាំមីនៗ ។

ដានី ៖ យើងឃាមមីនៗ?

វឿន ៖ មិនមែនឃាមមីនៗទេ គេឲ្យគ្រប់គ្រងនៅខាងក្រោយ ។

ដានី ៖ មីនៗនឹង គាត់ធ្វើអី មីនៗ?

វឿន ៖ មានស្ត្រីគ្រួសារ អឺ!កងកម្លាំងដែលនៅនឹងណា៎ ។

ដានី ៖ អូ! បានន័យថាមីនៗគ្រួសាររបស់កម្មាភិបាល អ្នកដែលធ្វើការនៅមន្ទីរ២៣នឹង?

វឿន ៖ បាទ!

ដានី ៖ ហើយចឹង គាត់ឲ្យពូអ្នកដឹកនាំមីនៗនៅនឹង អ្នកគ្រប់គ្រងមីនៗនៅនឹង?

វឿន ៖ បាទ!

ដានី ៖ ចុះពេលដែលយួនវៃចូលមកឆ្នាំ៧៩នេះ កាលនឹងប្រជាជនមិនរត់ទៅខាងដីថៃ?

វឿន ៖ បាទ!

ដានី ៖ ចុះមន្ទីរទៅណាវិញទៅ?

វឿន ៖ នៅដដែល ប៉ុនគ្រាន់ថាទៅនៅដីថៃ ។

ដានី ៖ នៅដីថៃ ដាក់ដីថៃវិញ?

រឿន :	បាទ! ដាក់ទៅថៃវិញ ។

ដានី :	ចឹងមន្ទីរនឹងឈ្មោះដដែលទេ គ្រាន់ដូរអីតាំង?

រឿន :	បាទ! ដូរទីតាំង ។

ដានី :	អ្នកទោសអីរាប់រយអ្នកដែរ?

រឿន :	មិនដល់ ច្រើន២០-៣០នាក់ ។

ដានី :	តាចាន់ គាត់ចេះដឹងច្រើន?

រឿន :	ច្រើន ។ ចុះគាត់គ្រូពីដើម សាស្ត្រាចារ្យ ។

ដានី :	គាត់កាច ហើយស្លូត នៅធ្វើការជាមួយពូ?

រឿន :	អឺ! មិនកាចអីប៉ុន្មាន ប៉ុនអ្នកខ្លះកាច អ្នកខ្លះថាមិនកាច ពូថាគាត់ចឹង គេខ្លាចគាត់ គ្រាន់តែពូឈ្មោះនឹងក៏គេខ្លាច ។

ដានី :	គ្រាន់ពូឈ្មោះតាចាន់ៗ គេខ្លាចគាត់?

រឿន :	បាទ!

ដានី :	ពូអត់ខ្លាចគាត់ទេ?

រឿន :	អត់ទេ ។

ដានី :	ចុះពូកាលជំនាន់៣ឆ្នាំ ពូដឹងថាតាចាន់គាត់ធ្វើអីដែរ?

រឿន :	អត់ដឹង ។

ដានី :	អត់ដឹងថាគាត់ធ្លាប់ធ្វើការនៅមន្ទីរសន្តិសុខស-២១ ហៅគុកទួលស្លែងនៅភ្នំពេញអី?

រឿន :	បាទ! អត់ដឹង ។

ដានី :	អនុប្រធានតាឌុចអីអត់ដែរដឹងទេ?

រឿន :	បាទ!

ដានី :	ដល់ក្រោយមកដឹងទេ?

រឿន :	ក្រោយមកដឹង ពូគាត់និយាយអីដឹងតើ ។

ដានី :	គាត់និយាយនៅណា?

រឿន :	គាត់និយាយតែនឹង គាត់និយាយថា កាលនឹងតាឌុចមានអីជាប្រធាន ប៉ុនគ្រាន់ដឹងតែប៉ុននឹង ។

ដានី :	និយាយពេលពូធ្វើការជាមួយគាត់?

រឿន :	បាទ! គាត់និយាយគ្នាគាត់ ។

ដានី ៖ ចឹងពូគ្រប់គ្រងមីង១រហូតដល់ពេលណា?

វឿន ៖ បាទ! រហូតដល់យើង ។

ដានី ៖ សមាហរណកម្ម?

វឿន ៖ បាទ!

ដានី ៖ ហើយមានពេលដែលវៀតណាមវៃចូលមកនៅនឹង យើងទៅនៅជីថៃឆ្នាំណា ពូចាំទេ?

វឿន ៖ ទេ! មិនដឹងឆ្នាំណា ៨០ប៉ុន្មានទេ ៨៥ដឹងអីមិនដឹង ។

ដានី ៖ ៨៥ ហើយយើងចូលមកវិញឆ្នាំ ចូលមកនៅជី?

វឿន ៖ ៩០ ៗ ។

ដានី ៖ មិនដឹង៩០ប៉ុន្មាន?

វឿន ៖ បាទ!

ដានី ៖ ដល់ពេលមកវិញ កន្លែងមន្ទីររបស់តាចាន់នឹងមកដាក់កន្លែងដដែលនឹង?

វឿន ៖ នឹងដាក់កន្លែងដដែល ។

ដានី ៖ ចំកន្លែងដដែល?

វឿន ៖ បាទ!

ដានី ៖ ចុះតាសុន សេន គាត់មកនៅនឹងបានយូរទេ?

វឿន ៖ អត់ដឹង ។

ដានី ៖ ពូដែលឃើញតាសុន សេនទេ?

វឿន ៖ អឺ! មិនដែលឃើញទេ ។

ដានី ៖ ចុះតាកន?

វឿន ៖ តាកន ខ្ញុំឃើញម្តងម្កាល ។

ដានី ៖ តាកន គាត់កាចហើយស្លូត?

វឿន ៖ ស្លូតមានអីគាត់ ។

ដានី ៖ គាត់ត្រូវជាម៉េចតាសុន សេន?

វឿន ៖ ដឹង ប្អូនមិនដឹង ខ្ញុំមិនដឹងដែរ ។

ដានី ៖ ចុះដល់ពេលសមាហរណកម្មហើយនឹង គុកនឹងគេរំសាយ ឬគេនៅបន្តទៀត?

វឿន ៖ រំសាយ ។

ដានី ៖ សមាហរណកម្មឆ្នាំនៅនឹង ពូ?

វឿន : អឺ! ដូច២០០០ ។

ដានី : ៩០ ហ៊ោ៎?

វឿន : ៩៦ ២០០៦នេះ ។

ដានី : ២០០៦?

វឿន : ហ៊ោ៎! ៩៦ ។

ដានី : ៩៦ ចុះពូមកនៅរស់នៅនឹងតាំងពីឆ្នាំណា ធ្វើផ្ទះធ្វើអីនៅនឹង?

វឿន : អឺ! ឆ្នាំនឹងឆ្នាំដែលអឺ! ឆ្នាំណា២០០០ប៉ុន្មានទេ ចុះកាលនឹងវាគ្រាន់តែមុនសមាហរណកម្ម តិច ។

ដានី : មុនសមាហរណកម្ម?

វឿន : បាទ!

ដានី : មុនសមាហរណកម្ម មកនៅនឹង?

វឿន : បាទ!

ដានី : សមាហរណកម្ម៩៦ ចឹងមុនឆ្នាំ៩៦?

វឿន : បាទ!

ដានី : មកធ្វើផ្ទះយើងចឹងម៊ង ឬក៏?

វឿន : នោះ ផ្ទះតូច ។

ដានី : កាលនោះយ៉ាងម៉េចដែរ នៅស្រុកភូមិយើងវាលល្ហូរល្ហេវចឹង នៅព្រៃនៅឡើយ?

វឿន : អានឹងនៅព្រៃវៀងច្រើន មិនទាន់វាលទេម្តុំខាងកើត ។

ដានី : នៅដែរ?

វឿន : អត់ ។

ដានី : ចុះពូយើងដូចថាដីធ្លីអីយ៉ាងម៉េច យើងចាប់ខ្លួនឯង ភ្ការវៀងខ្លួនឯង ឬក៏គេចែកឲ្យ?

វឿន : ដីកាលមុនសមាហរណកម្ម តាចាន់គាត់ចែកឲ្យ ។

ដានី : តាចាន់គាត់ចែកឲ្យ?

វឿន : បាទ! គាត់ចែកឲ្យ ។

ដានី : គេឲ្យប៉ុន្មានៗទៅ?

វឿន : ២ហិចតាម្នាក់ ។

ដានី : ម្នាក់២ហិចតា ដីចំការ?

វឿន :	ដីចំការ ។

ដានី :	ដីនៅត្រង់ណាទៅដី គាត់ចែកឲ្យ?

វឿន :	នៅនោះនៅតាមថ្នល់បត់ ។

ដានី :	តាចាន់ គាត់មានដីច្រើន?

វឿន :	ដីគាត់ មិនច្រើនប៉ុន្មានទេ តិចដែរ ។

ដានី :	ចុះយើង ដល់ពេលចែកឲ្យយើងចាប់ខ្លួនឯងទៀត ឬក៏អត់ទេ?

វឿន :	ក្រោយមកដល់សមាហរណកម្ម ខ្ញុំចាប់ខ្លួនឯង ។

ដានី :	ពូចាប់បានច្រើន?

វឿន :	ខ្ញុំគេឲ្យនឹង ខ្ញុំមិនទៅខ្លួនឯងកើតណាកាលនឹង វាមើលអត់ឃើញផង ។

ដានី :	បាទ! បានប៉ុន្មានហាត់ដែល មកដល់ឥឡូវ?

វឿន :	ដីតិចនឹង ដី៦-៧ហាត់ ។

ដានី :	ពូដាំដំឡូងបានច្រើន?

វឿន :	ដំឡូងបាន៥០រ៉ៃ នឹងមានដីតែប៉ុននឹង ។

ដានី :	ដាំទាំងអស់?

វឿន :	បាទ!

ដានី :	ឆ្នាំកន្លងមកទៅនេះដាំបានច្រើន?

វឿន :	អត់ខ្ញុំមិនដែលដាំ ជួលឲ្យគេ ។

ដានី :	ឆ្នាំនេះដាំខ្លួនឯង?

វឿន :	បាទ! អត់លុយធ្វើដើមទុន ។

ដានី :	ចុះពូថាកាលពីមុនសមាហរណកម្មអី តាសុន សេនមក ដូចថាកាលនឹងគាត់ម៉េច គាត់ឲ្យប្រជាជនមានរបស់របរយើងដាក់រួមដាក់អីឡើងវិញម៉េច យើងដឹង?

វឿន :	គេ ដូច អូ!កាលនឹងគេប្រមូលឡានប្រមូលអី ។

ដានី :	ម៉េចបានគេប្រមូលឡាន?

វឿន :	អត់ដឹងដែរ គោលការណ៍របស់គេ ខ្ញុំម៉េចដឹង ។

ដានី :	កាលនឹងពូអត់មានអី?

វឿន :	មានអី ។

ដានី :	អត់មានឡាន មានម៉ូតូអី?

វឿន ៖ សូម្បីតែកង់គ្មានផង ។

ដានី ៖ កាលនឹងអត់មាន?

វឿន ៖ ហ្នឹង ។

ដានី ៖ កាលនឹងប្រជាជនម៉េចដែល គាត់ពេញចិត្ត គេសប្បាយចិត្តអីដែរ អត់?

វឿន ៖ ចុះគេមានសប្បាយចិត្តអី ធម្មតារបស់គេ យកទៅចឹងម៉េចគេសប្បាយចិត្ត ។

ដានី ៖ តែគេអត់ហ៊ានប្រកែក?

វឿន ៖ បាទ!

ដានី ៖ ហើយចុះមានការប្រទូសប្រទះអីដែរ ឬយ៉ាងម៉េចដែល កាលជំនាន់នឹង?

វឿន ៖ ទេ អត់ទេ ដូចអត់មានអីទេ ។

ដានី ៖ ពូតាំងពីយើងសមាហរណកម្មមក ហើយយើងមានការខុសប្លែកគ្នាម៉េចទៅ កាលពីមុនយើងមិនទាន់សមាហរណកម្ម ការរស់នៅ?

វឿន ៖ បាទ! វាខុសគ្នា វាមិនដូចគ្នាទេ ។

ដានី ៖ ខុសគ្នាម៉េចទៅ?

វឿន ៖ ទី១កាលនោះ នៅជាអន្តភាព យើងមិនអាចថាធ្វើការងារអី រកស៊ីតាមចិត្តទេ ។ ហើយមកដល់ឥឡូវនេះយើងធ្វើអីក៏បាន មានសិទ្ធិសេរីភាពធ្វើទាំងអស់ កុំទៅលួចប្លន់គេ ។

ដានី ៖ តែអ៊ំជីវភាពនៅមានការរស់នៅកាលពីមុនៗសមាហរណកម្ម ហើយក្រោយសមាហរណកម្ម ជីវភាពដូចពូ គ្រួសារពូ គ្រួសារអ្នកផ្សេងទៀត យ៉ាងម៉េចដែរ?

វឿន ៖ ព្រោះកាលនោះនៅក្នុងរបបគេផ្គត់ផ្គង់ ទៅវាខ្វះខាត ហូបចុកវាម្យ៉ាង ប៉ុនរឿងអន្តរស្អីប៉ុនវាមិនពិបាកចិត្តពីរឿងខ្វះអន្តរហូបអីអត់ទេ ។

ដានី ៖ កាលនឹងរបបគេចែក?

វឿន ៖ បាទ!

ដានី ៖ ដល់ឥឡូវ?

វឿន ៖ ឥឡូវទាល់តែដោះស្រាយខ្លួនឯង វាមានការលំបាកខ្វះដែរ ។

ដានី ៖ បើតាមចិត្តពូ តាមចិត្តយើងចង់ថាកាលពីមុនសមាហរណកម្ម ពូចង់ថាស្រួលរស់នៅជាង ឬក៏ឥឡូវស្រួលរស់នៅ?

វឿន ៖ ឥឡូវស្រួលជាង ។

ដានី ៖ ពូចង់រស់នៅរបៀបឥឡូវជាង?

វឿន ៖ បាទ!

ដានី ៖ តែកាលពីមុនយើងមានរបបមានអី យើងមិន?

វឿន ៖ បាទ!

ដានី ៖ លោកពូខស្សាហ៍ទៅលេងស្រុកកំណើតដែរ?

វឿន ៖ អឺ! យូរៗទៅម្តងៗ

ដានី ៖ ចឹងពូបានទៅលេង ចឹងការតាំងពីបែកពីស្រុកដែលបានទៅលេងស្រុកលើកដំបូងឆ្នាំណា?

វឿន ៖ ឆ្នាំ១៩៧៧ មើល១៩៧ ដំបូងបង្អស់ហើយ។

ដានី ៖ ទៅលេង?

វឿន ៖ បាទ!

ដានី ៖ ពេលទៅដល់បងប្អូន ឪពុកម្តាយ គាត់ម៉េចដែរ?

វឿន ៖ គាត់ថាស្លាប់អស់ហើយ ធ្វើបុណ្យឲ្យខ្ញុំមិនដឹងប៉ុន្មានដងហើយទេ។

ដានី ៖ អូ! គាត់អត់ដឹង បាត់ដំណឹង?

វឿន ៖ បាត់យូរពេក។ កុំបានវះភ្នែកទេ បានភ្លឺកុំអីអត់បានទៅលេងស្រុកដែរ។

ដានី ៖ ហើយដល់ពេលពូទៅលេងស្រុកអីបានយូរថ្ងៃដែរ?

វឿន ៖ ៨-១០ថ្ងៃ។

ដានី ៖ ពូអត់ចង់ទៅរស់នៅស្រុកកំណើតវិញទេ?

វឿន ៖ អត់ចង់ទៅទេ។

ដានី ៖ ស្រុកកំណើតយ៉ាងម៉េច បើប្រៀបធៀបយើងស្រុកលោកពូ នៅផ្ទះយើងនៅនេះរាល់ថ្ងៃហ្នឹង ហើយនិងស្រុកកំណើតវាខុសគ្នាយ៉ាងម៉េចទៅ?

វឿន ៖ បាទ! ខុសគ្នា ព្រោះថាស្រុកខ្ញុំនៅនោះ វាតាំងពីដើមមកទៅដូចនៅដដែល វាគ្មានអីរីកចំរើនអីផល។ ចាញ់យើងនៅស្រុកនេះទើបប៉ុន្មានឆ្នាំ។

ដានី ៖ គ្រាន់បើចឹង?

វឿន ៖ បាទ!

ដានី ៖ នៅនោះតាំងពីពូចេញទៅ ដូចមិនសូវមានឃើញអីរីកចំរើន?

វឿន ៖ បាទ! គ្មានអីចំរើនដូចនៅ ចង់អន់ជាងមុនផង តាមស្រុកតាមផ្សារអីខ្លះ។ នឹកឃើញថានៅនឹងយូរហើយ គួរតែមើលទៅវារីកចំរើន។ អឺ! ឃើញឥឡូវវាបានផ្លូវ ប៉ុនទីផ្សារ ទីប្រជុំជនអីវាដូចដា។

ដានី ៖ អត់សូវប្លែកអី?

វឿន ៖ អត់មានអីប្លែក ។

ដានី ៖ ចុះមិត្តភ័ក្តអីកាលពីក្មេងៗស្របាលៗពូអីនៅស្រុកភូមិអីនៅមានដែរ ទៅឃើញពូនៅស្គាល់គ្នា នៅអីក៏អត់សូវមានទេ?

វឿន ៖ មិនសូវមានទេ ស្រករៗស្លាប់បាត់អស់ហើយ ។

ដានី ៖ អត់មានមិត្តភ័ក្តអីជិតស្និតនៅតាមស្រុកភូមិ?

វឿន ៖ បាទ!

ដានី ៖ ចុះបងប្អូនលោកពូ គាត់មានធ្លាប់អញ្ជើញមកលេងលោកពូអី?

វឿន ៖ អត់ដែលមកផង ។

ដានី ៖ មកដល់សព្វថ្ងៃនេះ ដូចខាងរាជរដ្ឋាភិបាល ហើយនិងអង្គការសហប្រជាជាតិ គេបង្កើតតុលាការមួយដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយណា ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើង នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពី៧៥ដល់៧៩នោះ ។ ហើយសព្វថ្ងៃនេះ គេខាងតុលាការនឹង គេបានជំនុំជម្រះទោសកាំង ហ្កេកអ៊ាវ ហៅឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស-២១ ហៅគុកទួលស្លែងនឹង គេបានជំនុំជម្រះទោសគាត់រួចហើយ ។ ហើយមេដឹកនាំជាន់ខ្ពស់ចំនួន៤រូប ដែលគេនឹងជំនុំជម្រះទោសគាត់នៅពេលឆាប់ៗខាងមុខនេះ មាននួន ជា, ខៀវ សំផន, អៀង សារី ហើយនឹងប្រពន្ធរបស់គាត់ គេនឹងជនុំជម្រះខាងមុខនេះ ។ តើចំពោះលោកពូវិញ លោកពូយល់ថាយ៉ាងម៉េចដែរ ការបង្កើតតុលាការសាលាក្តី ដើម្បីកាត់ទោសពួកគាត់នឹង តើវាសមត្រឹមត្រូវ សមរម្យដែរ ឬក៏មិនត្រឹមត្រូវទេ? បើតាមពូផ្ទាល់ បើតាមការយល់ឃើញរបស់ពូ?

វឿន ៖ បាទ! តាមការយល់ឃើញរបស់ខ្ញុំៗថា វាជាការត្រឹមត្រូវ ។

ដានី ៖ ម៉េចបានលោកពូយល់ឃើញថាជាការត្រឹមត្រូវ?

វឿន ៖ ពីព្រោះដែលខ្ញុំយល់ឃើញថាជាការត្រឹមត្រូវ សាលាក្តីខ្មែរក្រហមរកយុត្តិធម៌ជូនប្រជាជនដែលបានរកគ្រោះក្នុងរបប ។

ដានី ៖ ពូកាលតាចាន់ គាត់ត្រូវបានតុលាការគេអញ្ជើញគាត់ឲ្យនិយាយអី នៅក្នុងតុលាការនឹងកាលនឹងពូដឹងដែរ ពូបានបើកមើលទូរទស្សន៍ឃើញ?

វឿន ៖ បាទ! មើលឃើញ ។

ដានី ៈ កាលនឹង ពូឃើញ យល់ឃើញម៉េចដែរ?

វឿន ៈ កាលនោះខ្ញុំបើកទៅឃើញម៉ាភ្នែត មិនដឹងគាត់និយាយថាម៉េចដែរទេ គ្រាន់តែឃើញម៉ាភ្នែតដល់ចប់ទៅ ។ គាត់និយាយមិនដឹងថាគាត់និយាយអីខ្លះផង ស្ដាប់មិនបានផង បើទៅឃើញម៉ាភ្នែត ។

ដានី ៈ បាទ! ភាគច្រើន គាត់អត់សូវនិយាយស្អីផង ភាគច្រើនគាត់ថាគាត់ភ្លេច គាត់អត់ចាំចឹងពូជឿថាគាត់អត់ចាំ ឬក៏យ៉ាងម៉េច? ព្រោះគាត់ខ្ញុំឃើញខាងតុលាការគេសួរគាត់អីទៅភាគច្រើន គាត់ថាគាត់អត់ចាំទេ គាត់ភ្លេចហើយ យូរហើយ ។

វឿន ៈ បាទ! ខ្ញុំសន្និដ្ឋានថា បើខ្ញុំនៅក្មេងប៉ុននេះ ខ្ញុំនៅតែភ្លេច គាត់យូរទៅ ខ្ញុំភ្លេចអស់ច្រើនដែរ ប្រវត្តិដែលកន្លងមក ឆ្នាំ៧៧អីមកមិនសូវអីចាំ បាទ!ខ្ញុំភ្លេចដែរ ។ ហើយបើគាត់អាយុច្រើនប៉ុននឹង ខ្ញុំជឿងថាគាត់អាចភ្លេចដែរ ។

ដានី ៈ គាត់អាចភ្លេចដែរ?

វឿន ៈ បាទ!

ដានី ៈ ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំពូទៀតហើយ ចឹងពូមានអីចង់បញ្ជាក់បន្ថែមនូវអ្វីដែលពួកខ្ញុំអត់បានសួរនាំពូ?

វឿន ៈ បាទ! ខ្ញុំអត់មានអីបញ្ជាក់បន្ថែម ។

ដានី ៈ បាទ! ចឹងខ្ញុំអរគុណលោកពូច្រើន ដែលបានចំណាយពេលឲ្យខ្ញុំនេះបានសួរនាំទាក់ទងពីប្រវត្តិផ្ទាល់ខ្លួនរបស់លោកពូ ។

វឿន ៈ បាទៗ ។

ដានី ៈ បាទ! ខ្ញុំអរគុណលោកពូច្រើន ។

«ចប់»